ភ្នំពេញ, ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៥

# ការអញ្ជើញយុវជនចូលរួមក្នុងវគ្គបណ្តុះបណ្តាល
# ស្តីពី
# «ការផ្សព្វផ្សាយ និងប្រើប្រាស់វេទិកាសម្លេងម្ចាស់ឆ្នោត (Track MPs)»

គណៈកម្មាធិការដើម្បីការបោះឆ្នោតដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌ នៅកម្ពុជា(ខុមហ្វ្រែល) បានបង្កើតវេទិកាសម្លេងម្ចាស់ឆ្នោត(Track MPs) ដែលផ្តល់ឱកាសឲ្យប្រជាពលរដ្ឋម្ចាស់ឆ្នោត តាមដានសកម្មភាព ផ្តល់ពិន្ទុ និងលើកជាសំណួរទៅកាន់តំណាងរាស្ត្រតាមរយៈវេទិកានេះ។

អាស្រ័យដូចបានជំរាបជូនខាងលើ ខុមហ្វ្រែល មានកិត្តិយស សូមអញ្ជើញ**យុវជនចំនួន៧០នាក់** ដែលជាសិស្សនិស្សិត យុវជនបណ្តាញអង្គការសង្គមស៊ីវិលជាតិ-អន្តរជាតិ និងសាធារណៈជនជាយុវជនដទៃទៀត ដែលមានចំណាប់អារម្មណ៍ ចូលរួមក្នុងវគ្គបណ្តុះបណ្តាលយុវជនស្តីពី «**ការផ្សព្វផ្សាយ និងប្រើប្រាស់វេទិកាសម្លេងម្ចាស់ឆ្នោត** (Track MPs)»។

- កាលបរិច្ឆេទ ៖ ថ្ងៃ**សុក្រ** ទី**០៦** ខែ**វិច្ឆិកា** ឆ្នាំ២០១៥
- ពេលវេលា ៖ ម៉ោង ៨:០០ -១០:៣០ ព្រឹក
- ទីកន្លែង ៖ ស្នាក់ការអង្គការកម្មវិធីអភិវឌ្ឍន៍ធនធានយុវជន (YRDP)
  (ផ្ទះលេខ៩៣ ផ្លូវលេខ៥៩០ សង្កាត់បឹងកក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ)

## លក្ខខណ្ឌអ្នកចូលរួម និងអត្ថប្រយោជន៍ដែលទទួលបាន៖

- អ្នកមាន Smart Phone ឬ Laptop ព្រមទាំងមានឆន្ទៈផ្សព្វផ្សាយបន្តអំពីវេទិកាសម្លេងម្ចាស់ឆ្នោត (Track MPs)
- អ្នកនឹងទទួលបានចំណេះដឹងពីកម្មវិធីដែលអាចភ្ជាប់ទំនាក់ទំនងរវាងម្ចាស់ឆ្នោត និងតំណាងរាស្ត្រ
- អ្នកនឹងបានដឹងពីកម្មវិធី/របៀបផ្តល់មតិយោបល់ និងដាក់ពិន្ទុចំពោះអ្នកតំណាងរាស្ត្រដែលអ្នកពេញចិត្ត ឬមិនពេញចិត្ត

## ចុះឈ្មោះចូលរួម និងសួរព័ត៌មានបន្ថែមតាមរយៈ

ទូរស័ព្ទលេខ៖ **០១២ ៦៣ ០៥ ៣៣**

អ៊ីម៉ែល ៖ maliny@comfrel.org

Vision : A democratic society that democratization in particular democratic elections are promoted and qualified to bring benefits to people.

**បេសកកម្ម** ៖ បេសកកម្មរបស់ខុមហ្វ្រែល គឺជួយបង្កើតបរិយាកាសគួរជាទីពេញចិត្ត និងមានព័ត៌មានគ្រប់គ្រាន់ ទី១/**ដើម្បីឱ្យមានដំណើរការបោះឆ្នោតដោយសេរី និងយុត្តិធម៌** តាមរយៈការបញ្ចុះបញ្ចូល តស៊ូមតិ ដើម្បីទទួលបាននូវក្របខ័ណ្ឌច្បាប់សមរម្យ, ការអប់រំដើម្បីផ្តល់ព័ត៌មានដល់អ្នកបោះឆ្នោត អំពីសិទ្ធិ និងសកម្មភាពចូលរួមសង្កេតការណ៍របស់ពួកគេ ដែលអាចរារាំងនូវភាពមិនប្រក្រតី ព្រមទាំងផ្តល់នូវរបាយការណ៍អង្កេតយ៉ាងទូលំទូលាយ និងឆាប់រហ័ស ដើម្បីអាចឲ្យមានការវាយតម្លៃលើដំណើរការ បោះឆ្នោតមួយដែលមិនលំអៀង និងមិនប្រកាន់បក្សពួក ទី២/**ដើម្បីឱ្យមានអត្ថន័យនៃដំណាក់កាលក្រោយពេលបោះឆ្នោត** តាមរយៈការអប់រំ និងវេទិកាសាធារណៈក្នុងគោលបំណងជំរុញលើកទឹកចិត្ត ប្រជាពលរដ្ឋឱ្យចូលរួមក្នុងកិច្ចការនយោបាយ និងការធ្វើសេចក្តីសំរេចនានា ការតស៊ូមតិ/បញ្ចុះបញ្ចូលដើម្បីឱ្យមានការកែទម្រង់ ដំណើរការបោះឆ្នោតដែលបង្កើននូវគណនេយ្យភាព (ការទទួលខុសត្រូវ) របស់មន្ត្រីជាប់ឆ្នោត ព្រមទាំងផ្តល់នូវរបាយការណ៍អង្កេតយ៉ាងទូលំទូលាយ និងឆាប់រហ័ស ដើម្បីអាចឱ្យមានការវាយតម្លៃមួយដែលមិនលំអៀង និងប្រកាន់បក្សពួក ទៅលើការបំពេញកម្មវិធីនយោបាយ និងដំណើរការអនុវត្តន៍ការងាររបស់មន្ត្រីជាប់ឆ្នោត។

**ទីស្នាក់ការកណ្តាល** ៖ ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ ទឹកល្អក់ ១ ខណ្ឌ ទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
**Central Office : #138, Street. 122, Teuk Laak I, Tuol Kork, Phnom Penh, CAMBODIA.**
**P.O. Box** 1145, **Phone** : (855) 23 884 150 **Fax**: (855) 23 885 745 **E-mail** : comfrel@online.com.kh **Website**: www.comfrel.org